ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៣៤ សហវ.[illegible]

# ប្រកាស
# ស្តីពី
# ការប្រគល់សិទ្ធិជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ លើការបង្កើតវង្គទេយ្យបុរេប្រទាន និងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស០០៧/០៣២៣/រកម/ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៦២៤ សហវ.ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ចំពោះការបង្កើតរជ្ជទេយ្យបុរេប្រទាន និងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចាប់ពីឆ្នាំ២០២៤ តទៅដូចខាងក្រោម÷

**១.** ពិនិត្យ និងចុះហត្ថលេខា លើតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងលិខិតអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ គំរូតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងលិខិតអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត មានភ្ជាប់ជាឧបសម្ពន្ធទី១នៃប្រកាសនេះ។

**២.** ពិនិត្យ និងចុះហត្ថលេខា លើតារាងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងលិខិតអនុញ្ញាតឱ្យបង្កើតគម្រោងចំណាយ និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូងរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ គំរូតារាងគម្រោងចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងលិខិតអនុញ្ញាតឱ្យបង្កើតគម្រោងចំណាយ និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូងរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត មានភ្ជាប់ជាឧបសម្ពន្ធទី២នៃប្រកាសនេះ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃ ... ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០២៣*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:**

- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងគ្រប់រតនាគាររាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

(ឧបសម្ព័ន្ធទី១.១÷គំរូលិខិតអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

ថ្ងៃ...............ខែ............ ឆ្នាំ......... ព.ស.......

.......................ថ្ងៃទី.......ខែ...... ឆ្នាំ......

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ** ÷ ករណីសំណើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងសម្រាប់ឆ្នាំ ..........របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត.........។

**យោង**÷ - ប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

- លិខិតលេខ .......ចុះថ្ងៃទី.....ខែ........ឆ្នាំ........របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត........។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត....បង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ............ដែលមានទឹកប្រាក់ចំនួន..........រៀល(.....................រៀលគត់) និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងសម្រាប់ឆ្នាំ..........ចំនួន.....................រៀល (.....................រៀលគត់) ពីអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់មុខចំណាយដូចមានលម្អិតក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានភ្ជាប់ជាមួយ ដោយបង្វែរចូលគណនីរបស់រជ្ជទេយ្យករបុរេប្រទានលេខ.............. នៅធនាគារ.....................។

ការទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន ត្រូវធ្វើឡើងតាមអាណត្តិនិយតកម្ម ដើម្បីទូទាត់បំពេញបេឡារជ្ជទេយ្យបុរេប្រទាននិងជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានត្រឹមត្រូវតាមនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលនូវការរាប់អានពីខ្ញុំ

**ជ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

ចម្លងជូន÷
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត..........
- ឯកសារ-កាលប្បវត្តិ

(ឧបសម្ពន្ធទី១.២÷គំរូតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
សម្រាប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត....**

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ.....
## របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | **សរុបរួម** | | | | | | |
| ៦០ | | | **ការទិញ** | - | - | - | - | - | |
| | ៦០០១ | | សម្ភារៈផ្គត់ផ្គង់ថែទាំ | - | - | - | - | - | |
| | | ៦០០១១ | | | | | | | |
| | ..... | ..... | | | | | | | |
| ៦១ | | | **សេវាកម្ម** | - | - | - | - | - | |
| | ..... | ..... | | | | | | | |
| ៦៥ | | | **ឧបត្ថម្ភធន** | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ....... ខែ........ ឆ្នាំ......... ព.ស..
ថ្ងៃទី..... ខែ....... ឆ្នាំ....
ជ.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ....... ខែ........ ឆ្នាំ....... ព.ស..
ថ្ងៃទី..... ខែ....... ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ....... ខែ........ ឆ្នាំ....... ព.ស..
ថ្ងៃទី..... ខែ....... ឆ្នាំ....
ប្រធានមន្ទីរសហវ រាជធានី ខេត្ត...

ថ្ងៃ....... ខែ........ ឆ្នាំ......... ព.ស.
ថ្ងៃទី..... ខែ....... ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

(ឧបសម្ព័ន្ធទី២.១.១÷ គំរូលិខិតអនុញ្ញាតឱ្យបង្កើតគម្រោងចំណាយរៀបចំវគ្គបណ្តុះបណ្តាល/សិក្ខាសាលា/កិច្ចប្រជុំផ្សេងៗ និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូង របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

ថ្ងៃ............... ខែ............ ឆ្នាំ......... ព.ស........

...................... ថ្ងៃទី...... ខែ...... ឆ្នាំ......

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ** ÷ ករណីសំណើសុំបង្កើតគម្រោងចំណាយរៀបចំវគ្គបណ្តុះបណ្តាល/ សិក្ខាសាលា/ កិច្ចប្រជុំផ្សេងៗ និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូង សម្រាប់ឆ្នាំ.....របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត......។

**យោង** ÷ - ប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ

- លិខិតលេខ......ចុះថ្ងៃទី.....ខែ.....ឆ្នាំ....... របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត......។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត......បង្កើតគម្រោងចំណាយរៀបចំវគ្គបណ្តុះបណ្តាល/ សិក្ខាសាលា/ កិច្ចប្រជុំផ្សេងៗ សម្រាប់ឆ្នាំ........ដែលមានទឹកប្រាក់សរុបចំនួន..........រៀល (.................រៀលគត់) និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូង ដែលមានទឹកប្រាក់ចំនួន ......................រៀល (...................រៀលគត់) ពីអគ្គនាយកដ្ឋានរតនាគារជាតិ ដូចមានលម្អិតក្នុងតារាងឧបសម្ព័ន្ធគម្រោងចំណាយរៀបចំវគ្គបណ្តុះបណ្តាល/ សិក្ខាសាលា/ កិច្ចប្រជុំផ្សេងៗ ដោយបង្វែរចូលគណនីរដ្ឋទេយ្យករបុរេប្រទានលេខ............... នៅធនាគារ.....................................។

ការទូទាត់ចំណាយរៀបចំវគ្គបណ្តុះបណ្តាល/ សិក្ខាសាលា/ កិច្ចប្រជុំផ្សេងៗ ដែលអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនត្រូវធ្វើឡើងតាមអាណត្តិនិយតកម្ម ដើម្បីទូទាត់បំពេញបេឡា និងជម្រះបញ្ជីឱ្យបានត្រឹមត្រូវតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលនូវការរាប់អាន ពីខ្ញុំ

**ជ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

ចម្លងជូន÷
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...........
-ឯកសារ-កាលប្បវត្តិ

(ឧបសម្ពន្ធទី២.១.២÷គំរូគម្រោងចំណាយរៀបចំវគ្គបណ្តុះបណ្តាល/ សិក្ខាសាលា/ ប្រជុំផ្សេងៗ តាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត.......**

**គម្រោងចំណាយវគ្គបណ្តុះបណ្តាល/សិក្ខាសាលា/ប្រជុំផ្សេងៗតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ......**
**របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុន | ឥណទានថវិកាទូទាត់ត្រង់ | ឥណទានថវិកាបើកផ្តល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២/៤ |
| | | | សរុប | | | | |
| ៦១ | | | សេវាកម្ម | | | | |
| | ៦១០៤ | | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | | | | |
| | | ៦១០៤១ | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | | | | |
| | ៦១១០ | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | | | | |
| | | ៦១១០៣ | ប្រជុំ សិក្ខាសាលា និងសន្និសីទ | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.......ខែ........ឆ្នាំ.........ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ជ.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.......ខែ........ឆ្នាំ.......ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.......ខែ........ឆ្នាំ.......ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរសហវ រាជធានី ខេត្ត...

ថ្ងៃ.......ខែ........ឆ្នាំ.........ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋទេយ្យករបុរេប្រទាន

(ឧបសម្ព័ន្ធទី២.២.១÷គំរូលិខិតអនុញ្ញាតឱ្យបង្កើតគម្រោងចំណាយបេសកកម្មនៅក្នុងប្រទេស និង
បើកផ្តល់សាច់ប្រាក់មុនលើកដំបូង របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

*ថ្ងៃ............... ខែ............ ឆ្នាំ......... ព.ស........*

*...................... ថ្ងៃទី...... ខែ...... ឆ្នាំ.......*

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ÷** ករណីសំណើសុំបង្កើតគម្រោងចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូង សម្រាប់ឆ្នាំ.......... របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត........។

**យោង÷** - អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- លិខិតលេខ.....ចុះថ្ងៃទី....ខែ....ឆ្នាំ........របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត......។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...... បង្កើតគម្រោងចំណាយបេសកកម្មនៅក្នុងប្រទេសសម្រាប់ឆ្នាំ..........ដែលមានទឹកប្រាក់សរុបចំនួន........................... រៀល (................. រៀលគត់) និងបើកផ្តល់សាច់ប្រាក់មុនលើកដំបូង ដែលមានទឹកប្រាក់ចំនួន ......................... រៀល (................... រៀលគត់) ពីអគ្គនាយកដ្ឋានរតនាគារជាតិ ដូចមានលម្អិតក្នុងតារាងឧបសម្ព័ន្ធគម្រោងចំណាយបេសកកម្មនៅក្នុងប្រទេសដោយបង្វែរចូលគណនីរជ្ជទេយ្យករបុរេប្រទានលេខ...................................... នៅធនាគារ..........................។

ការទូទាត់ចំណាយបេសកកម្មនៅក្នុងប្រទេស ដែលអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនត្រូវធ្វើឡើងតាមអាណត្តិនិយតកម្ម ដើម្បីទូទាត់បំពេញបញ្ជី និងជម្រះបញ្ជីឱ្យបានត្រឹមត្រូវតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុនជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលនូវការរាប់អាន ពីខ្ញុំ

**ជ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

ចម្លងជូន÷
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត..........
-ឯកសារ-កាលប្បវត្តិ

(ឧបសម្ពន្ធទី២.២.២÷គំរូគម្រោងចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន
របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...**

**គម្រោងចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ....**
**របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...**

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | ឥណទានថវិកាបើកផ្ដល់សាច់ប្រាក់មុន | ឥណទានថវិកាទូទាត់ត្រង់ | ឥណទានថវិកាបើកផ្ដល់សាច់ប្រាក់មុនលើកដំបូង |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២/៤ |
| ៦១ | | | សេវាកម្ម | | | | |
| | ៦១១២ | | សោហ៊ុយបេសកកម្មក្នុងប្រទេស | | | | |
| | | ៦១១២១ | សោហ៊ុយដឹកជញ្ជូន | | | | |
| | | ៦១១២២ | សោហ៊ុយបេសកកម្ម | | | | |
| | | ៦១១២៣ | សោហ៊ុយស្នាក់នៅ | | | | |
| | | ៦១១២៨ | សោហ៊ុយក្នុងប្រទេសផ្សេងៗ | | | | |
| | សរុប | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.......ខែ........ឆ្នាំ.........ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ជ.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.......ខែ........ឆ្នាំ.......ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.......ខែ........ឆ្នាំ.......ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរសហវ រាជធានី ខេត្ត...

ថ្ងៃ.......ខែ........ឆ្នាំ.........ព.ស..
ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋលេខាធិការប្រធាន